ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០០២/២៥ ក.ប/វ.ល

## សារលិខិតជូនពរ

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត អនុប្រធានអចិន្ត្រៃយ៍**
**កាកបាទក្រហមកម្ពុជា និងជាអគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏នក្ខត្តឫក្សថ្លៃថ្លា ពោរពេញដោយក្តីអភិរម្យសោមនស្សរីករាយនៃខួបអាពាហ៍ពិពាហ៍ គម្រប់ ១៩ឆ្នាំ របស់ **សម្តេចធិបតី** និង **លោកជំទាវបណ្ឌិត** តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា ព្រមទាំងក្រុមគ្រួសារ សូមសម្តែងនូវសេចក្តីអំណរសាទរដ៏ស្មោះអស់ពីដួងចិត្ត និងសូមលើកហត្ថប្រណមបួងសួងគោរពជូនពរជ័យដល់ចំណងអាពាហ៍ពិពាហ៍របស់ **សម្តេចធិបតី** និង**លោកជំទាវបណ្ឌិត** សូមបរិបូរណ៍ដោយភាពផ្អែមល្ហែមត្រជាក់ត្រជុំដូចជាទឹកអង្គបំពង់ខ្វី សុខសុភមង្គលជាអមតៈ និងសូមទទួលបាននូវសុខភាពល្អ កាយពលមាំមួន ជន្មាយុយឺនយូរ និងបញ្ញាញាណភ្លឺថ្លាវាងវៃ ដើម្បីបន្តដឹកនាំប្រទេសប្រកបដោយកិត្តិបណ្ឌិត និងទំនួលខុសត្រូវខ្ពស់ លើការអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើនខ្លាំងក្លាជាសារវន្តលើគ្រប់វិស័យបន្ថែមទៀត។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏មហាមង្គលនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមជួយថែរក្សាអភិបាលប្រោះព្រំប្រសិទ្ធពរជ័យសព្វសាធុការជូន **សម្តេចធិបតី** និង**លោកជំទាវបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា និងជាអគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង ស៊ួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩